Developed by the
Minnesota Department of Health,
Tuberculosis Prevention and Control Program
August 2002 phone: (612) 676-5414

This is one in a series of four patient education pamphlets that addresses TB to be used in various clinical situations.

# ថ្នាំសំរាប់ ការកើតរោគ របេង

**Medicine for Tuberculosis Infection, Cambodian**

# ការកើតរោគរបេង

មន្ទីរព្យាបាលរបស់អ្នក បានពិនិត្យឃើញថា អ្នកមានការកើតរោគរបេង។ គេបានស្នើសុំឱ្យអ្នកប្រើថ្នាំសំរាប់ការពារកុំឱ្យអ្នកកើតជំងឺរបេង។

នៅពេលមួយកាលពីដើម អ្នកបានដកដង្ហើមដោយមេរោគរបេងចូលទៅក្នុងសួតរបស់អ្នក។ ខ្លួនអ្នកបានរក្សាទុកមេរោគរបេងនេះមិនឱ្យបង្កើនឡើង ឬធ្វើឱ្យអ្នកឈឺឡើយ។ មេរោគនេះមិនធ្វើសកម្មភាពសោះ ប៉ុន្តែវានៅរស់នៅឡើយនៅក្នុងខ្លួនរបស់អ្នក ដោយមិនធ្វើអ្វីឱ្យអ្នកឈឺឡើយ។ អ្នកមិនអាចចម្លងមេរោគរបេងនេះទៅអ្នកដទៃឯទៀតឡើយ។ របៀបនេះ គេហៅថា ការកើតរោគរបេង។

**ថ្នាំអាចការពារ អ្នកពីការកើត មានទូវជំងឺរបេង**

បើអ្នកមិនលេបថ្នាំសំរាប់ការពារការកើតរោគរបេងរបស់អ្នកទេនោះ អ្នកនឹងអាចទៅជាឈឺ ដោយមានជំងឺរបេង។ បន្ទាប់មក មេរោគរបេងអាចនឹងឆ្លងទៅអ្នកដទៃបាន។ ថ្នាំអាចការពារអ្នកមិនឱ្យកើតជំងឺរបេងបានដោយសម្លាប់មេរោគរបេងនោះ។ ការប្រើថ្នាំនេះ គេហៅថា វិធីព្យាបាលដោយប្រើថ្នាំសំរាប់ការពារ។

**សូមលេបថ្នាំទាំងអស់របស់ អ្នកដូចដែលពេទ្យបានចេញឱ្យ**

# វិធីព្យាបាលដោយប្រើថ្នាំការពារ

អៃសូនីញ៉ាហ្សីដ(INH) គឺជាថ្នាំដែលជាធម្មតាពេទ្យចេញសំបុត្រឱ្យ ក្នុងវិធីព្យាបាលដោយប្រើថ្នាំសំរាប់ការពារ។ ថ្នាំនេះសម្លាប់មេរោគក្នុងខ្លួនអ្នក។ ថ្នាំ *INH* នេះត្រូវតែប្រើតាមបញ្ជាសំបុត្រពេទ្យចេញឱ្យ ដោយមន្ទីរព្យាបាលរបស់អ្នក បើមិនដូច្នេះទេ វាមិនមានប្រសិទ្ធិភាពក្នុងការការពារជំងឺរបេងទេ។

មន្ទីរព្យាបាលរបស់អ្នក គេនឹងចង់ជួបអ្នក យ៉ាងហោចណាស់ ឱ្យបានមួយខែម្តង ក្នុងរយៈពេលធ្វើវិធីព្យាបាលដោយប្រើថ្នាំសំរាប់ការពារនេះ ដើម្បីមើលបញ្ជាក់ឱ្យច្បាស់ថា ខ្លួនអ្នកអាចទប់ទល់ជាមួយថ្នាំនេះ។

អ្នកអាចមានការធ្វើទុក្ខខ្លះៗអំពីថ្នាំ INHនេះ។ សូមទូរស័ព្ទ ឬទៅជួបនៅមន្ទីរព្យាបាលអ្នកភ្លាម បើអ្នកមានអាការរោគដូចខាងក្រោមនេះ:

- ចង្អោរ
- ក្អួត
- ពិសារអ្វីមិនបាន
- អស់កម្លាំងខុសប្លែកធម្មតា
- ឈឺពោះ
- ទឹកនោមឡើងពណ៌លឿងចាស់
- ស្បែក ឬភ្នែកឡើងពណ៌លឿង
- គ្រុនលើសពីពាថ្ងៃ
- ការឈឺផៀបៗតាមម្រាមដៃឬម្រាមជើង
- ចេញរមាស់លើស្បែក

ការពិសារគ្រឿងស្រវឹង(ស្រា ស្រាបៀរ និងស្រាផ្សេងៗ) នៅពេលអ្នកលេបថ្នាំ INH អាចបណ្តាលឱ្យមានការធ្វើទុក្ខកាន់តែច្រើនឡើង។ សូមជួបជាមួយមន្ទីរព្យាបាលរបស់អ្នក សំរាប់ព័ត៌មានបន្ថែម។